ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ

រៀបចំបុណ្យជាតិ-អន្តរជាតិ

លេខ:..០៥./.................គ.ជ.ប.អ.

/៥០២៦

# ផែនការណែនាំ
# ស្តីពី
# ការរៀបចំបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
# ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦

ជារៀងរាល់ឆ្នាំ ប្រជារាស្ត្រខ្មែរទាំងក្នុង និងក្រៅប្រទេស តែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិរបស់ខ្លួន ក្នុងមនោសញ្ចេតនាសប្បាយរីករាយ ប្រកបដោយស្មារតីសាមគ្គីភាពយ៉ាងជិតស្និទ្ធ។

ពិធីបុណ្យនេះ ប្រារព្ធឡើងដើម្បីទទួលអំណរ ស្វាគមន៍ចំពោះការចូលមកដល់នៃឆ្នាំថ្មី និងសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយ ប្រគេនព្រះពរ សម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក ព្រះសង្ឃគ្រប់ព្រះអង្គ ថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** និងជូនពរថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងបុព្វការីជនទាំងឡាយ មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ចាស់ព្រឹទ្ធាចារ្យជាដើម សំដៅបង្កើនឡើងនូវមនោសញ្ចេតនាគោរពស្រឡាញ់ សាមគ្គីភាពស្និទ្ធស្នាល និងទទួលបាននូវសព្ទសាធុការពរពីទេវតាឆ្នាំថ្មី ព្រះនាម **រាក្សសាទេវី**។

ពិធីបុណ្យចូលឆ្នាំថ្មី **ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦** នឹងប្រព្រឹត្តតាមដំណើរសង្ក្រាន្តដូចតទៅ ៖

* ថ្ងៃអង្គារ ១២រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦ វេលាម៉ោង ១០:៤៨នាទីព្រឹក ជាថ្ងៃចូលឆ្នាំថ្មី។
* ថ្ងៃពុធ ១៣រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦ ជាថ្ងៃវ័នបត។
* ថ្ងៃព្រហស្បតិ៍ ១៤រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៦ ជាថ្ងៃឡើងស័ក។ គម្រប់សង្ក្រាន្ត ៣ថ្ងៃ ចប់ដោយបរិបូណ៌ ចូលឆ្នាំមមី អដ្ឋស័ក តរៀងទៅ។

ដើម្បីរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ឱ្យស្របតាមប្រពៃណី ទំនៀមទម្លាប់របស់ជាតិ និងរក្សាឱ្យបានគង់វង្ស ប្រកបដោយភាពរុងរឿងនោះ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចខាងក្រោម៖



វិថីឧកញ៉ា ឈុន កែងផ្លូវវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

✱ <u>ក្រសួងព្រះបរមរាជវាំង</u>

រៀបចំព្រះរាជពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ **ឆ្នាំមមី អដ្ឋស័ក** ព.ស.២៥៧០ គ.ស.២០២៦ តាមព្រះរាជប្បវេណី និងតាមការសព្វព្រះរាជហឫទ័យ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

✱ <u>គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន</u>

រៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** និងព្រះបរមឆាយាល័ក្ខណ៍ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយមានតុបតែងលម្អកំណាត់បូ បំភ្លឺភ្លើងពណ៌ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ និងបដាពាក្យស្លោក ឱ្យបានស័ក្តិសម។

រៀបចំសារលិខិតថ្វាយព្រះរាជសព្ទសាធុការពរ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ **ឆ្នាំមមី អដ្ឋស័ក** ព.ស.២៥៧០ គ.ស.២០២៦។

✱ <u>រដ្ឋបាលរាជធានី ខេត្ត</u>

រៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** និងព្រះបរមឆាយាល័ក្ខណ៍ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយមានតុបតែងលម្អកំណាត់បូ បំភ្លឺភ្លើងពណ៌ និងលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក តាមគ្រប់មន្ទីរ អង្គភាព ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សាលារៀន វត្តអារាម និងណែនាំប្រជាពលរដ្ឋឱ្យលើកទង់ជាតិ គ្រប់គេហដ្ឋាន។

រៀបចំសារលិខិតថ្វាយព្រះរាជសព្ទសាធុការពរ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ **ឆ្នាំមមី អដ្ឋស័ក** ព.ស.២៥៧០ គ.ស.២០២៦។

ណែនាំម្ចាស់រោងចក្រ សហគ្រាស សាលារៀនឯកជន មណ្ឌលកម្សាន្ត រមណីយដ្ឋាននានា ឱ្យតុបតែងលម្អដោយទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងដុតគោម បំភ្លឺភ្លើងពណ៌ ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិយើង។

សហការការពាររក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ជួយសម្រួលចរាចរណ៍គ្រប់ទីកន្លែង ព្រមទាំងបង្កលក្ខណៈល្អប្រសើរ តាមមណ្ឌលកម្សាន្ត និងរមណីយដ្ឋាននានា ជូនប្រជាពលរដ្ឋ ភ្ញៀវជាតិ-អន្តរជាតិ ចូលរួមកម្សាន្តសប្បាយ។

រៀបចំឱ្យមានការលេងល្បែងប្រជាប្រិយរបស់ជាតិ ដូចជាបោះឈូង បោះអង្គុញ ទាញព្រ័ត្រ ទាត់សី លាក់កន្សែង រាំកម្សាន្ត តាមមណ្ឌលកម្សាន្ត តាមរមណីយដ្ឋាននានា ឬទីតាំងណាដែលសមគួរ ហើយជៀសវាង

និងទប់ស្កាត់ឱ្យបាននូវល្បែងណាដែលប្រាសចាកនឹងច្បាប់ ខុសប្រពៃណីជាតិ ដូចជាល្បែងស៊ីសង ល្បែងជះទឹកលាបម្សៅ និងគ្រឿងផ្ទុះផ្សេងៗ។ល។

ត្រូវយកចិត្តទុកដាក់បំផុតស្មារតីប្រុងប្រយ័ត្នក្នុងការដុតទៀន ធូប ភ្លើងចង្ក្រាន និងគ្រឿងឆេះផ្សេងៗដែលនាំឱ្យមានគ្រោះអគ្គិភ័យ។

រៀបចំពិធីបុណ្យសាសនា តាមវត្តអារាម និងពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធ បងប្អូនជនរួមជាតិ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ នៅកន្លែងដែលបានតម្កល់អដ្ឋិធាតុ នៅតាមបូជនីយដ្ឋាន ស្តូប និងវត្តអារាម។

រៀបចំកម្មវិធីចុះសួរសុខទុក្ខអ្នកជំងឺ ដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែក រាជធានី ខេត្ត និងចាស់ជរាគ្មានទីពឹង។

✱ <u>ក្រសួងធម្មការ និងសាសនា</u>

ណែនាំគ្រប់មន្ទីរធម្មការ និងសាសនា រាជធានី ខេត្ត រម្លឹកគ្រប់វត្តអារាមឱ្យធ្វើការសម្អាត និងតុបតែងលម្អដោយទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោកឱ្យបានសមរម្យ និងសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រៀបចំពិធីបុណ្យសាសនាតាមវត្តអារាមស្របតាមប្រពៃណីសាសនាប្រពៃណីជាតិ ដូចជាពិធីពូនភ្នំខ្សាច់ សម្អាតបរិស្ថានក្នុងវត្ត សម្អាតព្រះពុទ្ធរូប ព្រះបដិមា ពិធីស្រោចទឹកសីលវន្តសីលវតី មាតា បិតា ចាស់ព្រឹទ្ធាចារ្យជាដើម។ រៀបចំពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់វិញ្ញាណក្ខន្ធបងប្អូនជនរួមជាតិ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ នៅតាមទីកន្លែងដែលបានតម្កល់អដ្ឋិធាតុតាមបូជនីយដ្ឋាន ស្តូប និងតាមទីវត្តអារាម។

✱ <u>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ</u>

រៀបចំឱ្យមានកម្មវិធីប្រគំតន្ត្រីបុរាណ សម័យ ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ។

✱ <u>ក្រសួងព័ត៌មាន</u>

ចាត់អ្នកយកព័ត៌មាន និងទូរទស្សន៍ជាតិ ឱ្យចុះធ្វើសកម្មភាពថតរូប ថតទូរទស្សន៍ អំពីសកម្មភាព និងទិដ្ឋភាពក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ គឺថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០២៦ ដែលមានពិធីបុណ្យប្រពៃណីសាសនាតាមវត្តអារាម ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជូនប្រជារាស្ត្រ និងភ្ញៀវអន្តរជាតិទាំងក្នុងប្រទេស និងក្រៅប្រទេស បានទស្សនាយល់ជ្រួតជ្រាប។

✱ <u>ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ</u>

ជួយណែនាំអង្គភាពក្រោមឱវាទ ឱ្យសហការការពារក្សាសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គមចរាចរណ៍ ធានាបានសុវត្ថិភាពមុន ក្រោយ និងក្នុងពេលប្រារព្ធពិធីបុណ្យចូលឆ្នាំ នៅតាមវត្តអារាម មណ្ឌលកម្សាន្ត រមណីយដ្ឋាននានាក្នុងរាជធានី និងគ្រប់ខេត្ត។

សហការជាមួយរដ្ឋបាលរាជធានី ខេត្ត មានវិធានការទប់ស្កាត់ និងលុបបំបាត់នូវសកម្មភាពណាដែលល្មើសច្បាប់ ហើយប្រាសចាកនឹងប្រពៃណីទំនៀមទម្លាប់ជាតិ។

⁕ <u>គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ</u>

រៀបចំកម្មវិធីចុះសួរសុខទុក្ខបងប្អូនអ្នកមានជំងឺដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យនានា និងចាស់ជរាគ្មានទីពឹង ព្រមទាំងធ្វើទំនាក់ទំនងគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព ជួយឧបត្ថម្ភអំណោយជាសម្ភារៈ ថវិកា និងគ្រឿងឧបភោគបរិភោគ។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមនិងជឿជាក់ថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត នឹងយកចិត្តទុកដាក់អនុវត្តនូវផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ។

ថ្ងៃចន្ទ ៧កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦

**ជ.គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

**ប្រធាន**

**សម្តេចមហាមន្ត្រី គុយ សុផល**

**<u>ចម្លងជូន</u> ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
"ដើម្បីជូនជ្រាប"
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
"ដើម្បីសហការអនុវត្ត"
-ឯកសារ កាលប្បវត្តិ

# ពាក្យស្លោក

## សម្រាប់ប្រើក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

## ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦

១- សួស្តី ឆ្នាំថ្មី! ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦

២- សូមជូនពរឆ្នាំថ្មី ឆ្នាំមមី អដ្ឋស័ក សិរីសួស្តីជ័យមង្គល និងវិបុលសុខគ្រប់ប្រការ

៣- សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ បវរមហាប្រសើរ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦

៤- ឆ្នាំថ្មី ភារកិច្ចថ្មី ជ័យជម្នះថ្មី

៥- សូមថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** សូមមានព្រះរាជសុខកាពល្អ បរិបូរណ៍ និង ព្រះជន្មាយុយឺនយូរ

៦- សូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** សូមមានព្រះរាជសុខកាពល្អ បរិបូរណ៍ និង ព្រះជន្មាយុយឺនយូរ

៧- សូមថ្វាយព្រះរាជកុសល ព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** សូមបានយាងទៅសោយព្រះបរមសុខ ក្នុងសុគតិភព

៨- ជយោ! ព្រះរាជាណាចក្រកម្ពុជា

៩- ជាតិ សាសនា ព្រះមហាក្សត្រ

១០- ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

១១- ជយោ! ទិវាសន្តិភាពនៅកម្ពុជា

១២- អរគុណសន្តិភាព ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល នៃព្រះរាជណាចក្រកម្ពុជា

១៣- ជយោ! សន្តិភាព និងការអភិវឌ្ឍ

១៤- ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍

១៥- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

១៦- ជយោ! រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៧

១៧- មានសន្តិភាព ទើបមានការអភិវឌ្ឍប្រទេសជាតិ

១៨- សន្សំសំចៃ គឺស្នេហាជាតិ

១៩- ស្វាគមន៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦

២០- ជយោ! ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ គ.ស.២០២៦

២១- រួបរួមគ្នាថែរក្សាការពារប្រពៃណីទំនៀមទម្លាប់ អត្តសញ្ញាណជាតិ ឱ្យបានគង់វង្ស